ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-2013, 10:48
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ១៣: ៣២នាទី**

**សវនាការលើកទី១៩៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក មីរាម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ច័ន្ទ តារាស្មី

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ស៊ឹម ហោ (TCW-648) | ខ្មែរ |

# ខ្ញុំបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក ស៊ឹម ហោ** (TCW-648)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ .......... ទំព័រ ១
សួរដោយលោក គង់ សំអុន ផ្ដើមពី៖ .......... ទំព័រ ៤
សួរដោយលោក អាកទូរ វែកគែន ផ្ដើមពី៖ .......... ទំព័រ ១៧
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី៖ .......... ទំព័រ ២២

# កិច្ចដំណើរការនីតិវិធី

[១៣:៣១:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាង។ នៅរសៀលនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ឹម ហោ ហើយនិងសួរដេញដោលក្រុមមេធាវីការពារក្តី។ ប៉ុន្តែមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដែលលោកមានបំណងចង់តាំងសំណួរមួយ ឬក៏ពីរសំណួរទៅសាក្សីរូបនេះ។

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោក ស៊ឹម ហោ។ បាទ លោកមើលខ្ញុំអ្ហេះ? ខ្ញុំនៅចំពោះមុខលោកហ្នឹងហើយ។ ខ្ញុំលើកដៃ លោកឃើញទេ? ខ្ញុំមានសំណួរខ្លីទេ គឺខ្ញុំចង់បានការបញ្ជាក់របស់លោក ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានធ្វើនៅពេលដែលលោកចូលទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។

ខ្ញុំមានអារម្មណ៍ថាដូចជាមានឮអេកូ។ តើយើងអាចដោះស្រាយបញ្ហាបច្ចេកទេសនេះទេ គឺថាមានឮសំឡេងអេកូលាន់ចេញមកដូច្នេះពិបាកនិយាយណាស់។

*(មានបញ្ហាបច្ចេកទេស)*

[១៣:៣៣:២២]

លោកសាក្សី ខ្ញុំសូមឲ្យលោកជម្រាបជូនអង្គជំនុំជម្រះឲ្យបានច្បាស់អំពីអ្វីដែលលោកបានធ្វើនៅចន្លោះពេលដែលលោកមកទីក្រុងភ្នំពេញ គឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងពេលដែលលោកចាកចេញពីភ្នំពេញទៅកំពង់សោម គឺថាចន្លោះពេលហ្នឹង ហើយនិងទៅពេលទៅកំពង់សោម? លោកបានពន្យល់ថា លោកនៅគីឡូម៉ែត្រលេខ៦ ហើយបន្ទាប់មកទៀតទៅច្រាំងចំរេះ។ តើលោកមានទៅៗធ្វើការនៅកន្លែងណាផ្សេងទៀតទេ មុននឹងទៅកំពង់សោមនោះ?

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអរគុណ។ សូមជម្រាបប្រសាសន៍បន្ថែម ក្រោយរំដោះហៅថា០៧ មករា ក្រោយមក រំដោះទីក្រុងអស់ រំដោះទីក្រុងភ្នំពេញនេះ ឆ្នាំ៧៥នេះ ក្រោយមកគឺថាចេញពីគីឡូលេខ៦នោះ មិនទាន់ធ្វើជាកម្មករនៅឡើយទេ ច្រើនតែគឺបញ្ចូលមកនៅកន្លែងផ្សារចាស់យើង ដើម្បីគេរំសាយពីជួរកងទ័ព ប្រហែលជារយៈពេលកន្លះខែអ៊ីចេះ។ បាននៅម្តុំជ្រោយចង្វានេះឯង។ រួចហើយបានគេរៀបចំកម្លាំងនោះបញ្ជូនចេញទៅនៅកំពង់សោមបាទ។

[១៣:៣៥:០៨]

**ស៖** កាលពីម្សិលមិញលោកបានឆ្លើយថា មានមនុស្សម្នាក់ដែលទទួលខុសត្រូវកំពង់ផែកំពង់សោម ហើយមានការងារផងដែរនៅក្នុងក្រសួងពាណិជ្ជកម្ម លោកថា ឈ្មោះ តាញ៉ែម។ តើលោកនៅចាំឈ្មោះ តាញ៉ែម នេះទេ?

**ឆ៖** បាទ សូមបញ្ជាក់បន្ថែមចំពោះឈ្មោះ តាញ៉ែម នោះ ចាំបានតែទោះបីទៅធ្វើការនៅម្តុំកន្លែងនោះ ក៏យើងខ្ញុំមិនដែលបានឃើញគាត់ផ្ទាល់ទេ គ្រាន់តែដឹងថាឈ្មោះគាត់នេះឯងជាប្រធានក្រសួងពាណិជ្ជកម្មបាទ។

**ស៖** ចុះមុនពេលលោកចេញទៅកំពង់សោម តើលោកដឹងទេថា តាញ៉ែម មានទំនួលខុសត្រូវនៅក្នុងទីក្រុងភ្នំពេញដែរ។ គឺខ្ញុំចង់ដឹងថានៅពេលដែល តាញ៉ែម នៅក្នុងទីក្រុងភ្នំពេញតើគាត់ទទួលខុសត្រូវលើអ្វី? គឺគាត់មានមុខងារអ្វី?

**ឆ៖** មុននឹងចេញទៅទីក្រុងកំពង់សោម នៅក្នុងទីក្រុងភ្នំពេញអត់ទាន់បានឮឈ្មោះ តាញ៉ែម នេះទេបាទ ទាល់តែទៅនៅដល់កំពង់សោមទៅបានកងវរសេនាតូចរបស់យើងខ្ញុំនេះបានប្រាប់ថាការទទួលខុសត្រូវនៅតំបន់នោះគឺមានឈ្មោះ តាញ៉ែម ជាអ្នកទទួលគ្រប់គ្រងក្រសួងពាណិជ្ជកម្ម កម្មករទាំងអស់ដែលនៅកំពង់សោម ចាប់ពីឃ្លាំងលើទៅដល់ឃ្លាំងមាត់សមុទ្របាទ។

**ស៖** តើកម្មករឃ្លាំងទាំងអស់មកពីកងពលដែលស្ថិតនៅក្រោមឱវាទរបស់ភូមិភាគឧត្តរ។ តើអ៊ីចឹងមែនទេ? ហើយ តាញ៉ែម គាត់ក៏ជាសមាជិកនៃកងពលមួយដែលមកពីភូមិភាគឧត្តរដែរ។ តើអ៊ីចឹងមែនទេលោកសាក្សី?

**ឆ៖** បាទ សូមជម្រាបបន្ថែម គឺថាកម្លាំងដែលត្រូវនៅទីក្រុងកំពង់សោមដែលធ្វើជាកម្មករទាំងអស់នោះគឺទៅក្នុងកងពលភូមិភាគឧត្តរក៏ពិតមែន តែដោយឡែកឈ្មោះ តាញ៉ែម នេះមិនមែនជាមេ

កងពលរបស់យើងខ្ញុំពីមុនមកទេ តែការបែងចែកយ៉ាងម៉េចនោះ ក៏ខ្ញុំបាទមិនបានដឹងដែរគ្រាន់តែដឹងតាមរយៈកងវរៈរបស់យើងខ្ញុំបានប្រាប់ថាលោក តាញ៉ែម នេះជាអ្នកគ្រប់គ្រងនៅក្នុងកំពង់ផែកំពង់សោមទាំងអស់បាទ។

**ស៖** តើលោកដឹងទេថានៅពេលណាគេចាប់ខ្លួន តាញ៉ែម ហើយបើគេចាប់ខ្លួនគាត់នោះតើចាប់ខ្លួនដោយសារមូលហេតុអ្វី?

**ឆ៖** បាទ សូមបញ្ជាក់បន្ថែម។ ខ្ញុំបាទមិនបានដឹងកិច្ចការផ្ទៃក្នុងរបស់បក្សគេនោះទេ គឺគ្រាន់តែក្រោយមកដែលត្រឡប់មកដល់ទីក្រុងភ្នំពេញហើយបានទើបការលើកឡើងនេះរបស់ឈ្មោះ លោកតាវិទ្ធទេដែលនៅក្រសួងពាណិជ្ជកម្មដែលមកទទួលគ្រប់គ្រងបានឆ្លើយថា ឈ្មោះ ព្រំ ញ៉ែម អ៎! ឈ្មោះ ញ៉ែមនេះដែលទទួលបន្ទុកពាណិជ្ជកម្មនេះគេបានដកចេញហើយ។ អ៊ីចេះមានឈ្មោះ វិទ្ធ នេះជាអ្នកទទួលបន្ត។

**ស៖** តើលោកធ្លាប់ស្តាប់ឮថា តាញ៉ែម ត្រូវគេដកចេញដោយសារតែគាត់ជាប់ខ្សែក្បត់របស់កុយ ធួន ដែរឬទេ?

[១៣:៤០:០០]

**ឆ៖** បាទ សូមបញ្ជាក់បន្ថែម។ ត្រង់កិច្ចការនេះគឺខ្ញុំមិនបានដឹងទេត្រង់បញ្ហានេះ ប៉ុន្តែគ្រាន់តែថាការដកចេញគឺគាត់ជាប់ខ្សែក្បត់របស់ កុយ ធួន នេះឯង ព្រោះត្បិតអីនៅក្នុងភូមិភាគឧត្តរ គាត់នោះក៏ថានៅភូមិភាគឧត្តរដែរ។ អ៊ីចេះវាអាចមានការពាក់ព័ន្ធនឹងករណីនោះហើយបានគេដកចេញបាទ។

**ស៖** លោកក៏បាននិយាយអំពីឈ្មោះ ជា ដែលជាលេខារបស់ តាញ៉ែម ម្សិលមិញលោកនិយាយអំពីការចាប់ខ្លួន ជា។ តើលោកអាចនិយាយឡើងវិញបានទេថា មូលហេតុអីបានជាចាប់ខ្លួន ជា?

**ឆ៖** បាទ អានេះសូមបញ្ជាក់បន្ថែមថា មូលហេតុដែលចាប់ឈ្មោះមិត្តជា នេះ ព្រោះតែ មិត្តជាបើក្នុងសម័យនោះ គេហៅថា ជានីរសាររបស់តា ញ៉ែម ព្រោះ តាញ៉ែមនេះគេបានចាប់បាត់ហើយហេតុដូច្នេះដល់បន្តមកទៀតនេះឯង នៅ -- អាថានីរសារនេះគេត្រូវដកចេញ ចាប់ចេញទៅបាទ។ នេះគ្រាន់តែប៉ុណ្ណោះឯង ត្រង់យ៉ាងម៉េចយើងខ្ញុំមិនបានដឹងទេ កិច្ចផ្សេងទៀត។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយចំពោះសំណួររបស់ខ្ញុំ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៅនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៣:៤២:០៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ សូមគោរពលោក លោកស្រី ចៅក្រម។

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ ជាបឋម ខ្ញុំចង់សួរបញ្ជាក់លោកអំពីប្រវត្តិរូបរបស់លោក ដែលលោកបានឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះរួចហើយទាក់ទងទៅនឹងឯកសារ IS19.177 ត្រង់ទំព័រដំបូងគេគឺមានលេខ ERN ជាភាសាខ្មែរ 00053657, ជាភាសាបារាំង 00813944 ហើយអត់មានជាភាសាអង់គ្លេសទេ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីការកំណត់នូវកាលបរិច្ឆេទនៃពេលវេលាដែលលោកធ្វើការនីមួយៗនេះ តើលោកបញ្ជាក់តាមភាពជាក់ស្តែង ឬមួយក៏ជាការស្មាន ការវាយតម្លៃស្មានមិនមែនជាពេលវេលាជាក់ស្តែងទេ ដែលលោកបានផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែង និងពីដំបូងពីថ្ងៃទី១៥ ខែ៦ ឆ្នាំ៧២ ហើយលើកទី២ ថ្ងៃទី៣ ខែ២ ឆ្នាំ៧៤ ហើយលើកទី៣មានថ្ងៃទី៣ (សូមទោស) ខែ៣ ឆ្នាំ៧៥ ឃើញដាក់លេខ៣ អ៊ីចឹងជួរទី២ បន្ទាប់អ៊ីចឹងអាចជាខែ៣ ព្រោះអត់មានថ្ងៃ។

[១៣:៤៣:៤៣]

ទី៤ ថ្ងៃទី១៥ ខែ៥ ៧៥, ទី៥ ថ្ងៃទី២៨ ខែ៥ ឆ្នាំ៧៦, ទី៦ ថ្ងៃទី១៥ ខែ៦ ៧៥, ហើយទី៧ ថ្ងៃទី ១៧ ខែ៣ ៧៧, ថ្ងៃបន្ទាប់ទៀតចុងក្រោយគឺថ្ងៃទី២៨ ខែ៥ ៧៧។ អ៊ីចឹងខ្ញុំចង់សួរឲ្យលោកបញ្ជាក់ថា តើការកំណត់ពេលវេលានេះជាពេលវេលាដែលលោកចាំជាក់ស្តែង ឬមួយក៏ជាការដាក់តាមការស្មានរបស់លោកទេ សូមលោកជួយបញ្ជាក់។

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យលោកប្រធាន មុននឹងសាក្សីឆ្លើយ ខ្ញុំសូមបញ្ជាក់ប្រហែលជាការបកប្រែជាភាសាបារាំងពុំបានបញ្ជាក់ពីអត្តសញ្ញាណឯកសារ ខ្ញុំសូមបញ្ជាក់សាជាថ្មី គឺលេខ IS19.177។ បាទ

សូមអញ្ជើញលោកសាក្សី!

**លោក ស៊ឹម ហោះ**

**ឆ៖** បាទសូមអរគុណ សូមជម្រាបប្រសាសន៍។ ការដែលបានកំណត់ទៅតាមពេលវេលាថ្ងៃនេះ គឺតាមការចាំរបស់យើងខ្ញុំដែលត្រូវធ្វើការចាកចេញ និងការដែលធ្វើកន្លងទៅនឹងគឺអាចចាំតាមគោលៗ ត្រូវបានកត់ត្រា និងចំណាំទុកថា ចាប់ពីក្រោយរំដោះឆ្នាំ៧៥ទៅ ត្រឡប់ទៅនៅហៅថា កំពង់សោមអស់រយៈពេល១ឆ្នាំនោះ គឺយើងខ្ញុំចាំដោយខ្លួនឯងពិតប្រាកដបាទ។ ហើយត្រឡប់មកវិញក៏អាចចាំ បានន័យថា ទៅនៅឯណោះមួយរយៈទៅបាន១ឆ្នាំ គឺត្រូវវិលត្រឡប់មកវិញ អ៊ីចេះជាបន្តបន្ទាប់ ហើយមកនៅកន្លែងនីមួយៗ គឺតាមចំណុចៗដូចបានរៀបរាប់ខាងដើមក៏ពិតមែនដែរបាទ។

[១៣:៤៥:៥៤]

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចមកហើយដែរក្នុងពេលសវនាការកន្លងមកទាក់ទងទៅនឹងពេលវេលាមួយដែលលោកបានធ្វើទៅជាកម្មករនៅកំពង់សោម ហើយនៅពេលនោះ លោកបានជួបនឹងព្រឹត្តិការណ៍មួយ គឺការទម្លាក់គ្រាប់បែកតាមរយៈយន្តហោះ ហើយលោកបានឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះថាជាយន្តហោះអាមេរិកាំង។ តើលោកចាំបាននូវការថ្លែងផ្តល់សក្ខីកម្មរបស់លោកថា អ៊ីចឹងទេ?

**ឆ៖** បាទ ក្នុងនោះ គឺខ្ញុំចាំបានប្រាកដ ព្រោះវាជាក់ស្តែងទៅដល់មិនទាន់បានចាប់ផ្តើមធ្វើការទេ រយៈពេលប្រហែលជាបួនដប់ថ្ងៃជាងអ៊ីចេះ ដែលចុះទៅពីភ្នំពេញទៅដល់ទីក្រុងកំពង់សោមនោះឯង គឺថាយន្តហោះនោះបានទម្លាក់អ៊ីចឹងមែន។ ដល់ពេលទៅធ្វើការឃើញហេតុផលដែលវាធ្លាក់នៅ គឺថាមិនចំកប៉ាល់នុំងទេ គឺចំកន្លែងឃ្លាំងសម្រាប់ផ្ទុកអីវ៉ាន់នៅមាត់សមុទ្រនេះដែរបាទ។

[១៣:៤៧:០៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងកាលបរិច្ឆេទដែលលោកបានកំណត់នៅក្នុងទីកន្លែងធ្វើការក្នុងប្រវត្តិរូបរបស់លោកនេះ តើចំណុចមួយណាដែលលោកបញ្ជាក់ថាជាកន្លែងដែលលោកទៅធ្វើការនៅកំពង់ផែកំពង់សោមនោះ? ពីព្រោះនៅក្នុងប្រវត្តិរូបសង្ខេបរបស់លោកតាមការកំណត់នេះ គឺទំនងជានៅឆ្នាំ១៩៧៥ ដែលលោកទៅធ្វើការនៅកំពង់សោម ប៉ុន្តែការកំណត់ជាក់ស្តែង គឺអត់ឃើញថាថាកំពង់សោមទេ គឺមានដាក់ថា កម្មករ ក.ស – ប្រហែលជាក្រសួង ហើយក្រោមមកដាក់ពាណិជ្ជកម្ម នៅអង្គភាពពាណិជ្ជកម្ម ផ្នែក ក.ស។ ហើយថ្ងៃខែដែលលោកទៅចូលធ្វើការនៅទីនោះថ្ងៃទី១៥ ខែ៥

៧៥។ តើនេះជាកាលបរិច្ឆេទដែលលោកទៅកំពង់សោមនោះមែនទេ?

[១៣:៤៨:១៤]

**ឆ៖** បាទ សូមអរគុណ សូមជម្រាបបញ្ជាក់បន្ថែម។ កិច្ចការដែលពុំបានដាក់នោះ គ្រាន់តែជាការខ្វះចំណុចខ្លះដែលមិនបានពេញ គ្រប់លក្ខណៈសម្បត្តិក៏ពិតមែន តែក្នុងការងារគឺបានធ្វើជាកម្មករនៅកំពង់សោមពិតប្រាកដ ដូចបានបញ្ជាក់ក្នុងប្រវត្តិរូបអ៊ីចឹងមែនបាទ។

**ស៖** បាទ សូមលោកបញ្ជាក់ថា តើជាថ្ងៃទី១៥ ខែ៥ ឆ្នាំ៧៥ នោះមែនទេដែលជាថ្ងៃលោកទៅកំពង់សោម ទៅធ្វើជាកម្មករនៅកំពង់សោម?

**ឆ៖** បាទ ពិតជាថ្ងៃទី១៥ ខែ៥ ឆ្នាំ៧៥ មែន។

**ស៖** បាទ អម្បាញ់មិញលោកបញ្ជាក់ថា នៅពេលដែលលោកអញ្ជើញទៅដល់ប្រហែលជា១០ថ្ងៃ គឺមិនទាន់បានធ្វើការអីស្រួលបួលផង ហើយក៏មានយន្តហោះមកទម្លាក់គ្រាប់ត្រូវឃ្លាំងនៅកំពង់ផែនោះ។ អ៊ីចឹងមានន័យថា ការទម្លាក់គ្រាប់បែកពីលើយន្តហោះនោះស្ថិតនៅក្នុងចុងខែ៥ ឆ្នាំ១៩៧៥។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទៗ វាត្រឹមត្រូវហើយ គឺទៅដល់មិនទាន់បានធ្វើការទេ ដូចខ្ញុំបានរៀបរាប់ខាងដើមអ៊ីចេះឯង គឺថាបានរយៈពេលបានបួនដប់ថ្ងៃកន្លះខែហ្នឹង ខ្ញុំមិនបានចាំថ្ងៃពិតក្នុងពេលនោះ គឺមានយន្តហោះទម្លាក់អ៊ីចឹងមែនបាទ។ ព្រោះហេតុការណ៍នោះ ពិតជាក់ស្តែងអ៊ីចឹង។

[១៣:៥០:០១]

**ស៖** បាទ សូមអរគុណ។ តើការទម្លាក់គ្រាប់បែកពីលើយន្តហោះនេះ លោកបានឃើញផ្ទាល់នឹងភ្នែកដែរទេនៅពេលនោះ?

**ឆ៖** បាទ សូមបញ្ជាក់បន្ថែម។ គឺថាយន្តហោះបានក្រឡឹងឆ្វេល គឺនៅចម្ងាយពីឃ្លាំងលើទៅៗកន្លែងកំពង់ផែចម្ងាយ៧គីឡូម៉ែត្រ អាចអើតទៅវាលអ៊ីចេះមើលទៅឃើញបាទ ហើយឮសូរ។ ដល់ពេលទៅធ្វើការបានឃើញហេតុផលដែលកន្លែងទម្លាក់នេះ វាអាចផ្លាយអាកន្លែងឃ្លាំងសម្រាប់ផ្ទុកអីវ៉ាន់។

**ស៖** បាទ សំណួររបស់ខ្ញុំៗចង់សួរបញ្ជាក់ថា តើលោកបានឃើញយន្តហោះនោះ ពេលដែលហោះមកទម្លាក់គ្រាប់បែកហ្នឹងទេ ហើយឮសូរសំឡេងសន្ធឹករបស់យន្តហោះនោះ ដោយផ្ទាល់ខ្លួនរបស់លោកដែរទេ? លោកអាចបញ្ជាក់បានទេបាទ?

**ឆ៖** ឮសូរ ហើយឃើញរូបភាពយន្តហោះពិតមែនបាទ។

[១៣:៥១:០៣]

**ស៖** បាទ សូមអរគុណ។ មានយន្តហោះប៉ុន្មានគ្រឿងដែរលោក?

**ឆ៖** យន្តហោះតែមួយគ្រឿងទេបាទ។

**ស៖** លោកស្គាល់អត្តសញ្ញាណយន្តហោះហ្នឹងទេ ថាជាប្រភេទយន្តហោះអីដែរទេ?

**ឆ៖** មិនស្គាល់ទេ អត្តសញ្ញាណវា។ តែគ្រាន់ថាបានឃើញថាយន្តហោះនោះគឺផុនអាប្រដេញតាមរបៀបនេះ។ ទម្លាក់គ្រាប់បែកតែមួយគ្រឿងទេ អត់មានច្រើនទេ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចហើយកាលពីពេលកន្លងទៅថា មិនមានរបួសមនុស្ស ឬគ្រោះថ្នាក់ដល់អាយុជីវិតទេ។ ក៏ប៉ុន្តែខ្ញុំចង់សួរបន្ថែមថា ក្រោយពីមានការទម្លាក់គ្រាប់ហើយ តើលោកបានចូលទៅដល់ទីកន្លែលដែលជាកន្លែងធ្លាក់គ្រាប់បែកនោះដោយផ្ទាល់ឬទេ?

**ឆ៖** បាទ ក្រោយមក គឺថាកន្លែងដែលយន្តហោះបានទម្លាក់គ្រាប់បែកហើយ មិនអាចទៅភ្លាមទេ ជម្រាបប្រសាសន៍អ៊ីចេះ គឺថាហើយម្យ៉ាង។ ម្យ៉ាងទៀតទាល់រយៈពេលយូរដែរបានគេឲ្យកម្មករនេះទៅដូចថាដឹកសម្ភារៈជាស្បៀង អង្ករ អ្វីដែលចេញពីកប៉ាល់នោះមក យកមកដាក់ឃ្លាំងលើទៅ បានឃើញរូបភាពនោះពិតជាក់ស្តែងអ៊ីចឹងមែន។ តែត្រង់មានបញ្ហាគ្រោះថ្នាក់យ៉ាងម៉េចៗ មិនទាន់មានទេ អត់មានទេបាទ។ ខូចតែឃ្លាំងប៉ុណ្ណោះឯង។

[១៣:៥២:៥៨]

**ស៖** លោកអាចបញ្ជាក់ពីស្ថានភាពដែលលោកបានឃើញការខូចខាតនៅពេលដែលលោកអញ្ជើញទៅនោះបានទេ?

**ឆ៖** បាទ ការខូចខាតនោះ គឺខ្ញុំសូមបញ្ជាក់បន្ថែមឲ្យបានច្បាស់ថា ក្នុងពេលដែលទម្លាក់នោះអានេះយើងខ្ញុំមិនដឹងទេ តែជាគោលបំណងប្រុងដាក់ឲ្យចំកប៉ាល់ដែលផ្ទុកអីវ៉ាន់ មិនបានដាក់ចុះនេះទេ ប៉ុន្តែគ្រាប់នោះវាអាចផ្លោងមក វានៅជិតប្រហែលចម្ងាយពីៗមាត់សមុទ្រនឹងឃ្លាំងវាជាប់គ្នាដែរប្រហែលជាចម្ងាយ១០០ម៉ែត្រអ៊ីចេះ អ៊ីចេះអាចចុងឃ្លាំងនោះ អាចដាច់ធំណាស់ ទំហំវាគ្រាប់បែក ដាច់ធំអ៊ីចេះហើយអាក្រៅនោះ វារទីសរទុះ។ បាទសុទ្ធតែដែកនោះ ធ្លាយអស់។

**ស៖** បាទ សូមអរគុណ។ ហើយក្រោយពីការទម្លាក់គ្រាប់បែកនោះ មានកម្មាភិបាល ឬក៏អ្នកគ្រប់គ្រងនៅកន្លែងនោះហៅប្រជុំ ដើម្បីផ្តល់ព័ត៌មានអំពីបញ្ហាដែលកើតឡើងនោះទេ?

**ឆ៖** បាទ អ៊ីចេះ ខ្ញុំមិនបានកម្មាភិបាលណា ថ្នាក់លើឬក៏ខាងក្រោមហៅទៅប្រជុំប្រាប់ហេតុ

ផលយ៉ាងម៉េចគឺអត់ដឹង ព្រោះយើងជាកម្មករសុទ្ធសាធ គឺដល់ពេលសម្រាកការធ្វើការ គិតតែពីរឿងដល់ម៉ោងការងារគឺទៅធ្វើ តែសម្រាប់អ្នកធំខាងលើ គឺមិនដឹងគេប្រាប់គ្នាប្រជុំយ៉ាងម៉េច គឺអាហ្នឹងជារឿងដោយឡែក ខ្ញុំអត់បានដឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់ទៅនិយាយអំពីពេលមួយដែលលោកបានឃើញលោក ខៀវ សំផន មកកាន់ឃ្លាំងមួយនៅវត្តទួលទំពូង។ លោកចាំពីចំណុចនេះ ដែលលោកបានជម្រាបជូនអង្គសវនាការកន្លងមកទេ?

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ គឺខ្ញុំបានឃើញផ្ទាល់មែន ព្រោះពេលនោះ គឺថាកម្មករខាងសម្រិតសម្រាំងខាងអនុផលដែលត្រូវដែលថាវេចខ្ចប់ និងចេញទៅសម្រាប់បញ្ចេញទៅ ក្រៅដូចជាសណ្ដែក ជាអ្វីផ្សេងៗនោះ លោក ខៀវ សំផន នេះ បានធ្វើដំណើរដើរតាមដងផ្លូវអ៊ីចេះ គ្រាន់តែបានប្រាប់ ដូចខ្ញុំបានបញ្ជាក់កាលពីម្សិលមិញរួចហើយ។ គាត់បាននៅអីសំណេះសំណាលយកយូរទេ គ្រាន់តែប្រាប់ថា “កម្មករទាំងអស់ខំប្រឹងប្រែងធ្វើការ សម្រិតសម្រាំងឲ្យស្អាត។ អនុផលទាំងអស់នេះព្រោះចេញទៅក្រៅប្រទេស” តែប៉ុណ្ណោះឯង ពិតមែន។

**ស៖** បាទ សូមអរគុណ។ លោកស្គាល់លោក ខៀវ សំផន ពីមុនពេលដែលលោកជួបហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនដែលស្គាល់ទេ ទើបតែឃើញពេលនោះឯង។ ព្រោះមុននឹងដែលគាត់បានទៅពិនិត្យមើលផលិតផលដើរម៉ាឆ្វេតអ៊ីចេះទៅ ដោយការប្រជុំ ដូចខ្ញុំបានរាយប្រាប់ជម្រាបជូនហេតុផលដល់អង្គជំនុំជម្រះពីម្សិលមិញហើយថា លោក វ៉ាន់ រិទ្ធ ដែលជាប្រធានក្រសួងនោះបានជម្រាបថា ស្អែកនេះកម្មករទាំងអស់ត្រូវប្រឹងប្រែងធ្វើការឲ្យបានស្អាតៗ ព្រោះថា លោក ខៀវ សំផន លោកចុះមកត្រួតពិនិត្យផ្ទាល់។ អានេះអាចដឹងតាមរយៈនោះឯង បាទ បានស្គាល់នោះ។

[១៣:៥៦:៥៧]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់សាឡើងវិញ លោកមិនដែលបានស្គាល់លោក ខៀវ សំផន ពីមុនមកទៀត ប៉ុន្តែលោកបញ្ជាក់ថា មុន១ថ្ងៃ លោក វ៉ាន់ រិទ្ធ បានជម្រាបលោកអំពីការមកទស្សនកិច្ចរបស់លោក ខៀវ សំផន តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ ពិតមែនអ៊ីចេះឯង។

**ស៖** លោកចាំពីស្ថានភាពរូបរាងរបស់លោក ខៀវ សំផន នៅពេលនោះទេ?

**ឆ៖** បាទ ចាំ តាមមើលទៅ គាត់មិនជាធាត់ធំដូចគេទេ ស្គមស្តើងដែរ រាងគាត់។

**ស៖** បាទ សូមអរគុណ។ គាត់ស្លៀកពាក់យ៉ាងម៉េចដែរ លោកអាចចាំបានទេ?

**ឆ៖** គាត់ស្លៀកពាក់ គឺឯកសណ្ឋានខ្មៅអ៊ីចេះឯង ដើរទៅ។

**ស៖** ជាអាវធំ ដូចអាវរបស់លោកកំពុងតែពាក់ហ្នឹង? សូមលោកបញ្ជាក់សាឡើ។

**ឆ៖** បាទ គាត់ពាក់អាវធំអ៊ីចេះឯង ដូចខ្ញុំពាក់អ៊ីចេះឯង ដើរចេញទៅ។

[១៣:៥៨:៤២]

**ស៖** បាទ សូមអរគុណ។ ចុះខោ ស្បែកជើង--

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

ឆ្លើយ! សាក្សីឆ្លើយតបនឹងសំណួរ!

**លោក ស៊ឹម ហោះ**

**ឆ៖** ខោស្លៀកធម្មតា ប៉ុនខ្ញុំអត់បានចាំពិនិត្យអស់ទេ រឿងស្បែកជើង បានជាពិនិត្យដែរ មិនដឹងជាគាត់ពាក់ស្បែកជើងយ៉ាងម៉េចទេ ភ្លេចអស់ហើយកាលនោះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ គាត់មានពាក់វ៉ែនតាទេ ពេលហ្នឹង?

**ឆ៖** មិនចាំដែរ ប៉ុនដូចជាមិនឃើញពាក់ទេ វ៉ែនតា។

**ស៖** បាទ សូមអរគុណ។ លោកធ្លាប់ឮឈ្មោះពីមុនមកទេ ជាពិសេសមុនពេលដែលលោកបានជួបគាត់នៅទួលទំពូងហ្នឹង?

[១៤:០០:០៦]

**ឆ៖** បាទក្នុងនោះ ខ្ញុំធ្លាប់តែតាមរយៈដែលប្រជុំក្នុង១ខែដែលសម្រាកបីដង ១០ថ្ងៃប្រជុំម្តង។ គឺបានលើកដូចបានជម្រាបប្រសាសន៍ពីម្សិលអ៊ីចេះឯង តាមលំដាប់ថ្នាក់ដឹកនាំទាំងប៉ុន្មានរូបនោះ ដោយលោក វ៉ាន់ រិទ្ធ ដែលជាប្រធានគ្រប់គ្រងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេសនេះ បានប្រាប់ហេតុផលកម្មករទាំងអស់បានស្គាល់ បានដឹង។

**ស៖** សូមទោស ខ្ញុំស្តាប់លោកអត់បានលោក។ លោកនិយាយថា លោកបាន -- ព្រោះសំណួរខ្ញុំ ខ្ញុំសួរថាតើលោកបានស្គាល់ឈ្មោះលោក ខៀវ សំផន ពីមុនមកទេ? បើខ្ញុំមិនច្រឡំទេ អំមិញលោក

និយាយពីរឿងប្រជុំដែលលោក វ៉ាន់ រិទ្ធ បានប្រាប់។ លោកអាចបញ្ជាក់បានទេថា លោកស្គាល់ លោក ខៀវ សំផន ពីមុន អាចថាពីមុនឆ្នាំ១៩៧៥។ តើលោកធ្លាប់បានស្គាល់ទេ? ធ្លាប់ឮឈ្មោះគាត់ទេ?

[១៤:០១:១០]

**ធ៖** បាទសូមអរគុណ សូមបញ្ជាក់បន្ថែម។ មិនស្គាល់ តែគ្រាន់តែឮឈ្មោះ ខៀវ សំផន ឮយូរហើយបាទ។

**ស៖** បាទសូមអរគុណ។ លោកដឹងថាលោក ខៀវ សំផន មានឋានៈអី តួនាទីអីដែរក្នុងពេលមុនឆ្នាំ១៩៧៥ ពេលដែលលោកឮហ្នឹង?

**ធ៖** បាទសូមជម្រាបប្រសាសន៍បន្ថែម គឺថាជំនាន់នោះ គឺមិនចាំបាច់តែរូបខ្ញុំទេ សម្រាប់ប្រជាជនក៏គេអាចឮថា ឈ្មោះលោក ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ដែរ។ បាទយូរហើយៗ មិនដឹងជាទទួលតំណែងមុខងារម៉េច គឺអត់ដឹង។ អានេះដឹងតែពីថាឮឈ្មោះ គឺយូរតាំងមុនឆ្នាំ៧៥ ក៏ឮដែរ។ តែមិនដែលឃើញទេ។

**ស៖** បាទសូមអរគុណ។ លោកមានដែលធ្លាប់ឮពាក្យថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែរឬទេ ហ្រ្គុង ពាក្យថា “ហ្រ្គុង” អក្សរកាត់ជាភាសាបារាំង?

[១៤:០២:២៧]

**ធ៖** សូមអធ្យាស្រ័យ ស្តាប់អត់បាន អាហ្នឹងអត់ច្បាស់។

**ស៖** ខ្ញុំសួរថាលោកដែលឮពាក្យថា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិដែរឬទេ ហើយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិនេះ ជាភាសាកាត់ អក្សរនោះគេហៅថា “ហ្រ្គុង”?

**ធ៖** បាទខ្ញុំចាំមិនបានអស់ទេបាទ សូមជម្រាបប្រសាសន៍។

**ស៖** បាទសូមអរគុណ។ លោកដែលឮពាក្យថារណសិរ្សរួបរួមជាតិដែរទេ?

**ធ៖** រណសិរ្សរួបរួមជាតិ គឺបានឮទៅតាមការប្រជុំមួយលើកៗដែរ បាទដែលប្រាប់ហ្នឹង។

[១៤:០៣:៣០]

**ស៖** បាទសូមអរគុណ។ លោកឮពីពេលណាដែរ?

**ធ៖** បាទឮពេលដែលធ្វើកម្មករនេះនៅក្នុងទីក្រុងភ្នំពេញដែរ នៅម៉ុំទួលទំពូងបាទ ដែលលោក វ៉ាន់ រិទ្ធ លោកបាននិយាយប្រាប់ចុងឆ្នាំ៧៩ហ្នឹងបាទ។

**ស៖** លោកឮដំបូងនៅឆ្នាំណា? ឆ្នាំ៧០ ចុងឆ្នាំ៧៩ ឬមួយក៏ឮនៅពេលណាលោក សូមលោក

បញ្ជាក់សាជាថ្មី?

**ឆ៖** ឮក្នុងឆ្នាំ៧៩ នេះឯងបាទ។ សូមបញ្ជាក់អ៊ីចឹង ដើមឆ្នាំ មិនមែនចុង។

**ស៖** ដើមឆ្នាំ៧៩ហ្នឹង ពេលណាដែរ ខែណាដែរ លោកអាចបញ្ជាក់បានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់និយាយ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាណក្រហមនៅក្បាលមីក្រូហ្វូន ឬក៏ប៊ូតុងនៅពីខាងក្រោមនេះ សឹមនិយាយណ៎ះ!

[១៤:០៥:០៧]

**លោក គង់ សំអុន៖**

**ស៖** បាទសូមលោកជួយឆ្លើយលោកឮពីពាក្យថា "រណសិរ្សរួបរួមជាតិ"ហ្នឹងនៅខែណា នៅក្នុងឆ្នាំ៧៩នោះ?

**ឆ៖** ខ្ញុំមិនបានចាំខែទេ មិនដឹងជាខែ ១ ឬខែ២ ប៉ុន្តែក្នុងដើមឆ្នាំ៧៩ដែរ។ ចាំមិនបានអស់។

**ស៖** លោកចាំបានថាអ្នកណាជាអ្នកនិយាយប្រាប់លោកពីរឿងរណសិរ្សរួបរួមជាតិនេះទេ?

**ឆ៖** ចាំតាមរយៈកាលប្រជុំក្នុងថ្ងៃ១០, ថ្ងៃ២០ ក្នុងមួយខែ បីដងដែលតាមលោក វ៉ាន់ រិទ្ធ ហ្នឹងឯងជាអ្នកផ្សព្វផ្សាយបន្តមក។

**ស៖** អ៊ីចឹងបានន័យលោកដឹងតាមរយៈលោក វ៉ាន់ រិទ្ធ? តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ពិតជាត្រឹមត្រូវបាទ។

**ស៖** លោកស្គាល់លោក វ៉ាន់ រិទ្ធ ដំបូងនៅថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនបានចាំប៉ុនតាំងពី អូ! បើនិយាយទៅឆ្នាំ៧៧ ដែលគាត់ទទួលតំណែងប៉ុន្តែមិនដឹងខែណាដែរទេ?

**ស៖** បាទ អរគុណ។ លោកមានដឹង ឬក៏ធ្លាប់ឮឈ្មោះលោក វ៉ាន់ រិទ្ធ មុនឆ្នាំ១៩៧៧ ដែរទេ?

**ឆ៖** បាទ មិនដែលឮដែរមុនឆ្នាំ៧៧ អត់ដែលឮឈ្មោះ វ៉ាន់ រិទ្ធ នេះទទួលមុខងារយ៉ាងម៉េចអត់ដឹងដែរ ទើបតែឃើញនិងដឹងថា ថ្ងៃក្រោយមកគឺគាត់មកកាន់ការងារមុខតំណែងខាងពាណិជ្ជកម្មតែម្តង។

**ស៖** បាទ សូមអរគុណ។ លោកបានឆ្លើយបញ្ជាក់មុននេះបន្តិចថា លោក វ៉ាន់ រិទ្ធ ជាអ្នកប្រជុំប្រាប់លោកអំពីរណសិរ្សរួបរួមជាតិនៅក្នុងដើមឆ្នាំ៧៩។ ខ្ញុំចង់សួរលោកថា ដោយតាមរយៈប្រវត្តិរូបរបស់លោកដូចខ្ញុំបានបង្ហាញជូនលោកមុននោះ លោកបានចូលធ្វើយោធាតាំងពីថ្ងៃទី១៥ ខែ៦ ឆ្នាំ៧២

អ៊ីចឹងខ្ញុំចង់សួរថានៅក្នុងឆ្នាំ១៩៧២ តើលោកធ្លាប់ឮពាក្យថារណសិរ្សរួបរួមជាតិនោះទេ នៅពេលដែលលោកផ្តើមចូលធ្វើយោធា?

**ឆ៖** បាទ ចំណុចនេះគឺយើងខ្ញុំមិនបាចាំនោះទេ តែគ្រាន់តែចាំបានថាគេប្រមូលកម្លាំងយុវជនដើម្បីធ្វើកងទ័ពរ៉ៃ លន់ នល់ ហ្នឹងហើយបាទ។

**សះ** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីរឿងទឹកន្លែងនៅវត្តទួលទំពូងវិញ។ លោកបានបញ្ជាក់ហើយថាលោកបានឃើញលោក ខៀវ សំផន ដើរមកហើយបាននិយាយជាមួយកម្មករពីរបីម៉ាត់ថា “ឲ្យខំធ្វើការ” ជាដើម ហើយក៏ដើរហួសទៅ។ សូមលោកបញ្ជាក់ថាអ្នកណាខ្លះដើរជាមួយគាត់នៅពេលនោះ?

**ឆ៖** បាទសូមអរគុណ។ សូមជម្រាបប្រសាសន៍បន្ថែម គឺមិនមានគ្នាច្រើនទេគឺមានតែលោក វ៉ាន់ រិទ្ធ, បន្ទាប់ក្រោយបន្តមកទៀតគឺថា សម័យនោះគេហៅថា នីរសារអមដំណើរ គឺមានពីរនាក់បីនាក់ ប៉ុណ្ណោះឯងបន្តពីក្រោយមក ដើរដាច់ៗឆ្ងាយៗពីគ្នា។

**សះ** បាទ សូមអរគុណ។ អ្នកណាគេជានីរសារ? នីរសារហ្នឹងជានីរសាររបស់អ្នកណាលោកអាចបញ្ជាក់បានទេ?

**ឆ៖** សូមអរគុណ។ ខ្ញុំមិនស្គាល់ទេបាទ សម្រាប់ហៅថាថ្នាក់ដឹកនាំធំគឺអត់ស្គាល់ គ្រាន់តែដឹងថាឲ្យតែដើរពីក្រោយគឺប្រាកដជានីរសាររបស់អ្នកធំអ៊ីចឹងតែម្តងបាទ។

**សះ** អ៊ីចឹងខ្ញុំសរុបសម្តីរបស់លោកឡើងវិញ។ ខ្ញុំនិយាយត្រូវទេថាអ្នកដែលដើរជាមួយលោក ខៀវ សំផន នាពេលនោះមានលោក ខៀវ សំផន, លោក វ៉ាន់ រិទ្ធ, ហើយនិងមានអ្នកផ្សេងពីរនាក់ ឬក៏បីនាក់ទៀត តាមអ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:១១:១១]

**សះ** ពេលលោកឆ្លើយជូនអង្គសវនាការកន្លងមក លោកបានបញ្ជាក់នូវកាយវិការមួយដែលលោក វ៉ាន់ រិទ្ធ បានធ្វើចំពោះលោក ខៀវ សំផន គឺលោក វ៉ាន់ រិទ្ធ ដើរពីក្រោយលោក ខៀវ សំផន ហើយដើរឱនក្បាល។ តើអ៊ីចឹងត្រឹមត្រូវទេ អ្វីដែលលោកជាអ្វីដែលលោកបានមានប្រសាសន៍កន្លងមកមែនទេ?

**ឆ៖** បាទនោះគឺជារឿងពិត ព្រោះដើរឱនជារហូតអ៊ីចេះតែម្តងពីក្រោយលោក ខៀវ សំផនមក។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតឲ្យសាក្សីអាចបង្ហាញកាយវិការដែលលោក វ៉ាន់ រិទ្ធ ដើរពីក្រោយលោក ខៀវ សំផន ឱន ដោយរបៀបយ៉ាងម៉េច? បានទេ លោកប្រធាន សូមអនុញ្ញាត?

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១២:៣៩]

**ប្រធានអង្គជំនុំ៖**

សំណើរបស់លោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន ចុងក្រោយនេះមិនសមស្របទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សីធ្វើដូច្នេះទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកសាក្សីលោកអាចបញ្ជាក់បានទេថា ការដែលលោក វ៉ាន់ រិទ្ធ ដើរពីក្រោយលោក ខៀវ សំផន ហើយឱននោះ។ ឱនក្នុងលក្ខណៈយ៉ាងម៉េចដែរលោកអាចរៀបរាប់បានទេ?

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ សូមអរគុណ។ សូមបញ្ជាក់បន្ថែម ឱននោះវាមិនជាការអ្វីនេះទេ វាយើងនិយាយទៅថា ក្នុងន័យគោរព ការទាបហើយនិងខ្ពស់។ បាទ ខ្ញុំសូមឆ្លើយដោយខ្លីប៉ុណ្ណេះបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចមើលពី -- ដឹងថាលោក វ៉ាន់ រិទ្ធ មានអាយុប៉ុន្មានដែរ ដោយសារលោក វ៉ាន់ រិទ្ធ ជាអ្នកធ្វើការជាមួយលោក ជាមេរបស់លោកផ្ទាល់?

**ឆ៖** ស្មានមិនត្រូវទេ បើអានេះការប៉ាន់ស្មានប្រហាក់ប្រហែលជាអាយុ៥០ប្លាយ បើតាមខ្ញុំមើលមាឌគាត់ទាប ហើយមាឌរាងក្រអាញដែរ ធំ មធ្យមដែរ។

**ស៖** បាទ សូមអរគុណ។ ចុះបើប្រៀបធៀបលោក វ៉ាន់ រិទ្ធ និងលោក ខៀវ សំផន តើមួយណាចាស់ជាង តាមដែលលោកបានឃើញផ្ទាល់ចំពោះរូបរាងគាត់ទាំងពីរនាក់នោះ?

**ឆ៖** បាទ សូមអរគុណ។ លោក ខៀវ សំផន រាងស្តើងស្គម ខ្ពស់ជាង តែបើនិយាយពីយុវវ័យប្រហាក់ប្រហែល បើសិនជាបងក៏បងតិចតួចទេ តាមខ្ញុំប៉ាន់ស្មាននេះ អានេះមិនអាចត្រូវទេ ព្រោះអត់ដឹង។

**ស៖** បាទ សូមលោកបញ្ជាក់ឲ្យច្បាស់អ្នកណាបងបន្តិចបន្តួច?

**ឆ៖** បាទ សូមអធ្យាស្រ័យ។ លោក ខៀវ សំផន ប្រហាក់ប្រហែលជាបងមួយឆ្នាំ ឬក៏ពីរឆ្នាំ អានេះការប៉ាន់ស្មាន មិនអាចត្រូវទេ។

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំត្រឡប់ទៅនិយាយពីជិតពេលដែលការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបានបញ្ជាក់កន្លងមកថា លោកបានចូលរួមប្រជុំជាមួយលោក ខៀវ សំផន នៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៩។ តើលោកចាំថាលោកបានផ្តល់សក្ខីកម្មទាក់ទងនឹងចំណុចនេះជូនអង្គជំនុំជម្រះទេ?

[១៤:១៦:៣១]

**ឆ៖** បាទ សូមអរគុណ។ សូមបញ្ជាក់បន្ថែម គឺថាបានបញ្ជាក់ជូនដូចបានលើកឡើងពីម្សិល។ គឺថាបានទៅចូលរួមអ៊ីចឹងមែនអំពីការអប់រំផ្សព្វផ្សាយរបស់គាត់ថា អ៊ីចេះអ៊ីចុះ អាហ្នឹងគឺត្រឹមត្រូវហើយ ដូចខ្ញុំបានលើកឡើងអ៊ីចេះឯងពីម្សិលមិញបាទ។

**សៈ** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់អំពីទីកន្លែងដែលលោកបានចូលរួមប្រជុំជាមួយលោក ខៀវ សំផន បានទេ?

**ឆ៖** កន្លែងដែលប្រជុំដូចចាំមិនសូវបានច្បាស់ ក្នុងមួយកន្លែងបុរីកីឡាអ៊ីចេះ? មិនដឹងទេ ខ្ញុំឆ្លើយអត់ច្បាស់អាត្រង់ម្តុំនេះវាភ្លេចទៅយូរដែរ។

**សៈ** លោកចាំថា នៅម៉ោងប៉ុន្មានទេនៅពេលដែលប្រជុំហ្នឹង?

**ឆ៖** ពេលដែលប្រជុំនោះមិនបានចាំទេ ប៉ុន្តែគ្រាន់ថា ប្រហាក់ប្រហែលជាពេលព្រឹក ប៉ុន្តែមិនដឹងជាម៉ោងប៉ុន្មានចាំអត់បានច្បាស់បាទ។

**សៈ** បាទ តាមខ្ញុំស្តាប់ឮអ្វីដែលលោកបញ្ជាក់អម្បាញ់មិញ គឺប្រជុំនៅពេលព្រឹក ប៉ុន្តែលោកមិនចាំម៉ោងច្បាស់ទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះខ្ញុំមិនអាចចាំបានទេ ត្រង់ម៉ោងបាទ។ បើព្រឹកៗហើយមិនដឹងជាម៉ោងថ្ងៃប៉ុន្មានណា ហួស។

[១៤:១៨:៤៥]

**សៈ** លោកអាចបញ្ជាក់ពីរយៈពេលនៃការប្រជុំហ្នឹងបានទេ ចាប់ពីម៉ោង អាចរយៈពេលប៉ុន្មានម៉ោងដែរ បើសិនជាលោកមិនចាំម៉ោងចាប់ផ្តើមពិតប្រាកដ?

**ឆ៖** ប្រហែលជារយៈពេល១ម៉ោងកន្លះអីទេបានបែកគ្នាបាទ។ តាមការប៉ាន់ស្មាន មិនចាំប្រាកដ

ទេបាទ ប៉ុន្តែអត់យូរដែរ។

**ស៖** បាទ សូមអរគុណ។ លោកធ្លាប់បានបញ្ជាក់ថា មានអ្នកផ្សេងទៀតចូលរួមច្រើនពីអង្គភាពផ្សេងៗ។ តើលោកអាចបញ្ជាក់ពីចំនួនអ្នកដែលចូលរួមហ្នឹងថាមានប៉ុន្មាននាក់ទេ តាមការប៉ាន់ស្មានដែលលោកអាចប្រមើលមើលឃើញនៅពេលនោះ?

[១៤:១៩:៥១]

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ ខ្ញុំមិនបានរាប់ទេ តែចំនួនច្រើនដែរបាទ មកពីក្រសួងផ្សេងមិនតែក្រសួងពាណិជ្ជកម្មមួយកន្លែងទេ ក្រសួងដឹកជញ្ជូន ក្រសួងណាៗ ផ្សេងៗនោះមកគេមកចូលរួមទាំងអស់គ្នាទៅ ឃើញថាមនុស្សច្រើនដែរ ប្រហែលជាចូលក្បែររយដឹង ខ្ញុំមិនបានរាប់ដែររាប់រយ ព្រោះវាអត់ដឹង ព្រោះអីមិនមែនទៅនេះទេបាទ។ មិនអាចច្បាស់ទេត្រង់ហ្នឹង ច្រើនៗដែរបាទ។ មិនមែនប្អូនដប់នាក់ទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីសណ្ឋាន ទីតាំងដែលលោកបានប្រជុំនោះទេ? លោកមិនចាំទីតាំងពិតប្រាកដទេ តែលោកអាចចាំជាសណ្ឋានរបស់អគារ ជាជញ្ជាំង ឬដំបូល ជាទ្រង់ទ្រាយដែលអាចធ្វើឲ្យលោកនៅចាំបានទេ? មានសណ្ឋានបែបម៉េចដែរ កន្លែងទីតាំងប្រជុំហ្នឹង?

**ឆ៖** សូមអធ្យាស្រ័យមិនអាចចាំបានទេ យូរហើយខ្ញុំភ្លេចៗអស់។

[១៤:២១:២៥]

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ថាលោក ខៀវ សំផន ជាអ្នកទៅដឹកនាំប្រជុំនៅពេលនោះ។ មានអ្នកណាផ្សេងទៀត ក្រៅពីលោក ខៀវ សំផន ទេ នៅពេលហ្នឹង?

**ឆ៖** ពេលនោះ តាមដឹង តាមឃើញទៅ ឃើញតែគាត់ម្នាក់ហ្នឹងឯងទេ មិនមានអ្នកផ្សេងទេ។ មានតែលោក ខៀវ សំផន ម្នាក់ហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ ពេលដែលលោកទៅ លោក ខៀវ សំផន ទៅដល់ តើលោក ខៀវ សំផន គាត់និយាយអ្វី ចាប់ផ្តើមពាក្យពេចន៍អ្វីនៅពេលដែលបើកការប្រជុំដំបូងនេះ? លោកចាំទេ?

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ គឺថាពេលនោះខ្ញុំមិនបានរៀបរាប់នឹងចាំអស់គ្រប់ឃ្លាទេ តែគ្រាន់តែយល់ដឹងចំណុចៗសំខាន់ៗ គាត់បានលើកថា ឲ្យមិត្តឯងទាំងអស់ត្រឡប់ទៅវិញ ត្រូវដឹកលេណដ្ឋាន ទោះបីយន្តអាមេរិកាំងទម្លាក់នៅម្តុំអរិយក្សត្រខាងមុខរដ្ឋសភានេះក៏ដោយ គឺថាយើងត្រូវតែតតាំងជាដាច់ខាត។ តែប៉ុណ្ណោះទេ ខ្ញុំចាំបានតែប៉ុណ្ណោះឯងទេ។

[១៤:២៣:០៦]

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់ ថាតើខ្លឹមសារដែលលោក ខៀវ សំផន ដែលលោកថាលោក ខៀវ សំផន និយាយនៅពេលនោះ ជាការដើម្បីត្រៀមទូវ តតាំងនៅភ្នំពេញតទៅទៀត ឬមួយក៏ជាព័ត៌មានដើម្បីឲ្យត្រៀមដកខ្លួនថយចេញពីភ្នំពេញ? សូមលោកបញ្ជាក់។

**ឆ៖** បាទ សូមបញ្ជាក់បន្ថែមថា លក្ខណៈឲ្យជីកលេណដ្ឋាននេះ មិនដឹងជាបានអីទប់ទល់ទេ ខ្ញុំមិនដឹងដែរ ព្រោះកម្មករជាអ្នកលីសែង បើគ្រាន់ថាឲ្យត្រៀមលក្ខណៈជីកលេណដ្ឋានកុំឲ្យរត់។ តែវាមិនដឹងជាស្ថានភាពយ៉ាងម៉េច។ ហេតុដូច្នេះគឺថាចុងបញ្ចប់ចេញមកវិញ គឺជំនុំគ្នាថាមិនដឹងជាផ្លូវណាទេ យើងរាល់គ្នាទាំងអស់គ្នានេះ បើគាត់លើកឡើងយ៉ាងដូច្នោះ។ អ៊ីចេះបានន័យថា សង្គ្រាមអាចកើតតទៅទៀតហើយ។

**ស៖** លោកចាំបានទេថា អ្នកណាខ្លះពីអង្គភាពរបស់លោកបានទៅចូលរួមប្រជុំនៅពេលនោះ?

**ឆ៖** ត្រង់ចំណុចនេះ ខ្ញុំចាំអត់បានអស់ទេ។ តែការរួមរស់នៅជាមួយគ្នាក៏មិនស្គាល់គ្នាអស់ដែរ។ ឥឡូវនេះវាទៅជាភ្លេចអស់ហើយ មនុស្សច្រើន។ វានៅចម្រុះគ្នាទាំងឧត្តរ ទាំងបូព៌ាទៅ។ ដល់បែកយូរអ៊ីចេះ បាត់មិនស្គាល់ទេអស់ទេ។ ខ្ញុំចាំអត់បានអស់ទេ។ ទៅគ្នាច្រើនដែរ។

[១៤:២៥:១១]

**ស៖** បាទ សូមអរគុណ។ តើលោក នៅពេលដែលលោកទៅចូលរួមប្រជុំនោះ មានការពិភាក្សាគ្នាអំពីការវ៉ៃចូលរបស់កងទ័ពវៀតណាមនៅពេលនោះទេ?

**ឆ៖** បាទ ជាបន្តពេលនោះមក ក្រោយពីការប្រជុំរួចផុតរំលងបាន១ថ្ងៃ ដល់មកថ្ងៃទី០៦ គឺថាការវិលត្រឡប់សួរកាំភ្លើងពីខាងកើតនេះ វាចេះតែឮសូរកិតមក គ្រាំៗអ៊ីចេះតែម្តង ហើយការជម្លៀសចេញស្ទើរល្ងាចប្រហែលជាម៉ោងប្រាំ គឺកុមារកុមារីចេះតែមកពួនតាមផ្លូវទួលទំពូងនេះ ធ្លាប់មកស្នឹងមានជ័យយើងពីដើម ឥឡូវក៏ខ្ញុំអត់ស្គាល់ដែរ ព្រោះអត់ចាំកន្លែង ប៉ុនថារត់ចូលគ្នាមក។ បានថាសកម្មភាពនេះ គឺអាចប្រែប្រួលមែនពិតដូចការលើកឡើងអ៊ីចេះមែន។

**ស៖** ការប្រែប្រួលយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** ការប្រែប្រួលនោះ កាលពីថ្ងៃ០៥ដែលប្រជុំថា បើយន្តហោះទម្លាក់គ្រាប់បែកក៏ដោយ ឲ្យជីកលេណដ្ឋានដើម្បីការពារ។ អ៊ីចេះលុះបានតែ១ថ្ងៃព្រឹកឡើង គឺមានសភាពការណ៍ប្រែប្រួលអ៊ីចេះតែម្តង មនុស្សរត់ប្រទាំងប្រទើស។ បាទ អានេះឯងជាសកម្មភាពការណ៍ប្រែប្រួល។

**ស៖** បាទ សូមអរគុណ។ តើពេលនោះមានយន្តហោះទម្លាក់គ្រាប់បែកដែរទេនៅទីក្រុងភ្នំពេញ?

**ឆ៖** រឿងយន្តហោះ យើងខ្ញុំក្តាប់មិនបានទេ។ តែគ្រាន់តែថាពេលដែលព្រឹកឡើងម៉ោងប្រាំពីរ គឺអាចរត់តែម្តង រត់ចេញពីទីក្រុងទៅពោធិ៍ចិនតុង។ អ៊ីចេះមិនទាន់ដល់ស្ទឹងមានជ័យប៉ុស្តិ៍វិទ្យុ គេថាកាំភ្លើងធំរបស់កងទ័ពវៀតណាមផ្តោងចូលចំកណ្តាលផ្សារថ្មី ឮសូរផ្សែងហុយ ក៏ពីតនាំគ្នាគិតតែពីរត់យកតែម្តង របូតខោរបូតអាវតែម្តង គេដោយគេ ឯងដោយឯង។

**ស៖** បាទសូមអរគុណ។ ចុះថ្ងៃទី០៥ ពេលដែលលោកប្រជុំហ្នឹង មានឮគ្រាប់កាំភ្លើងធំធ្លាក់នៅកន្លែងណាដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ស៊ឹម ហោ៖**

**ឆ៖** អានោះឮសូរដែរ តែវាឮសូរល្វើយៗ ដូចថាគេថាអ្នកលឿង ខ្ញុំមិនដែលទាំងស្គាល់អ្នកលឿងផង គេថាម្ខាងទន្លេ។ ដល់យប់បន្តិចទៅវាចេះឮសូរជិតឡើងៗអ៊ីចឹងតែម្តង។

[១៤:២៨:៣៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក ស៊ឹម ហោ ខ្ញុំអស់សំណួរហើយ។

លោកប្រធាន ខ្ញុំអស់សំណួរ។ សូមអរគុណ។

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី ខ្ញុំឈ្មោះ អាក់ទួរ វែកគែន។ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ បាទ ខ្ញុំសួរសំណួរតិចតួចទេ។ ដើម្បីជាកិច្ចចាប់ផ្តើម ខ្ញុំសូមចាប់បន្តនិយាយអំពីកិច្ចប្រជុំដែលលោកបានចូលរួមមុនពេលដែលវៀតណាមចូលមកដល់ ហើយនៅក្នុងកិច្ចប្រជុំនោះ លោក ខៀវ សំផន ទំនងជាផ្តល់សារមួយ។ អ៊ីចឹងខ្ញុំចង់យល់ថា លោកនិយាយថាក្នុងកិច្ចប្រជុំនោះ លោក ខៀវ សំផន បានសុំឲ្យពួកលោកទាំងអស់គ្នាតស៊ូប្រឆាំងនឹងពួកវៀតណាម ឲ្យជីកត្រង់សេអីជាដើមនេះ។ អ៊ីចឹងមែនទេ?

**លោក ស៊ឹម ហោះ**

**ឆ៖** បាទ ពិតមែន ថាឲ្យជីកលេណដ្ឋានការពារ ក្រែងយន្តហោះទម្លាក់មក គឺសំឡេងហ្នឹង គឺប្រាកដជាគាត់និយាយអ៊ីចឹងតែម្តង។

[១៤:៣០:០០]

**ស៖** បាទ អ៊ីចឹងគឺថាការជីកលេណដ្ឋាននៅកន្លែងដែលលោកនៅហ្នឹង បានន័យថានៅជុំវិញភ្នំពេញហ្នឹងមែនទេ?

**ឆ៖** បាទ អរគុណ។ ឲ្យជីកលេណដ្ឋានកន្លែងរស់នៅកន្លែងកម្មករនៅរៀងៗខ្លួនឲ្យប្រយ័ត្នក្រែងលោគ្រាប់ផ្លោង ឬក៏យន្តហោះទម្លាក់។

**ស៖** បាទ បើខ្ញុំយល់មិនខុសទេ គឺថាអ្វីដែលលោកនិយាយអម្បាញ់មិញគឺថាគោលបំណងគឺការពារខ្លួនឯង ឬក៏មានបំណងអីខុសពីហ្នឹងទៀត?

**ឆ៖** បាទ អានេះបើតាមការយល់របស់យើងខ្ញុំ គឺថាគាត់ប្រាប់នេះសម្រាប់ការពារខ្លួនឯងក្រែងលោវាមានគ្រោះថ្នាក់ ព្រោះកន្លងទៅវាកើតសង្គ្រាម ដល់នេះសង្គ្រាមវាត្រូវដល់ ត្រូវតែមានលេណដ្ឋានការពារ។

**ស៖** បាទ សូមអរគុណ។ បើសិនជាខ្ញុំនិយាយខុសសូមលោកកែប្រែ។ អ៊ីចឹងគឺថាគោលបំណងគឺថាគ្រាន់តែការពារខ្លួនឯងទេ មិនមែនបានន័យថាប្រឆាំងនឹងវៀតណាមវិញទេ អ៊ីចឹង?

**ឆ៖** បាទ និយាយនោះមិនដឹងនិយាយប្រឆាំង ឬមិនប្រឆាំងទេ គ្រាន់តែថាឲ្យជីកលេណដ្ឋានសម្រាប់ជ្រកនៅការពារគ្រាប់រំសេវ ឬក៏ទម្លាក់គ្រាប់បែកនោះឯងបាទ។ ប៉ុន្តែប្រឆាំងអីបើកម្មករមានអាវុធឯណា អត់ប្រឆាំងដែលរឿងច្បាំង រំសាយអស់ហើយ។

**ស៖** បាទ ខ្ញុំសូមអរគុណ។ តើនៅក្នុងពាក្យពេចន៍របស់លោក ខៀវ សំផន នៅពេលនោះបើសិនជាលោកចាំនោះ តើគាត់មានបានផ្តល់ជាដំបូន្មានដល់បុគ្គលមួយចំនួនឲ្យចាកចេញពីទីក្រុងភ្នំពេញសិនដែរឬទេ? គឺថារត់ចេញពីទីក្រុងភ្នំពេញតែម្តង?

**ឆ៖** អត់មានប្រាប់ថាឲ្យចាកចេញទេ ប៉ុន្តែរត់ចេញនេះតាមហេតុផលជាក់ស្តែង។ ព្រឹកឡើងថ្ងៃ០៧ ដឹងថាគេថា យួនចូលមក គឺនាំគ្នារត់ប្រាសអាយុ យកតែអាយុរៀងខ្លួនតែម្តង។ អានេះដឹងតែប៉ុណ្ណោះឯង ព្រោះនៅម៉េចកើតគ្រាប់មកដល់ហើយ មានអីតតាំងបើមិនរត់។

**ស៖** បាទ នៅពេលដែលលោកផ្តល់ចម្លើយឲ្យអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

លោកបាននិយាយពីព្រឹត្តិការណ៍ហ្នឹងដែរ។ លោកនិយាយថាបើតាមលោកដឹង មេដឹកនាំផ្សេងៗទៀតនោះបានចាកចេញពីទីក្រុងភ្នំពេញហើយនៅថ្ងៃប្រជុំនោះ។ តើលោកនៅចាំទេ លោកបាននិយាយយ៉ាងដូច្នេះទៅកាន់អ្នកស៊ើបអង្កេតនៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** សំណួរនេះខ្ញុំក្តាប់មិនសូវបាន។

**ស៖** បាទ នៅឆ្នាំ២០០៣ មានគេមកសម្ភាសលោកដើម្បីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយពេលនោះលោកបាននិយាយថា មុនពេលវៀតណាមចូលមកនោះលោកបានចូលប្រជុំជាមួយលោក ខៀវ សំផន។ លោក ខៀវ សំផន បាននិយាយហើយថា កាលនោះអ្នកផ្សេងៗទៀតនោះគេបានចាកចេញពីទីក្រុងភ្នំពេញអស់ហើយ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកចាំទេ ចាំថាបាននិយាយយ៉ាងដូច្នេះទៅគេទេ?

លោកព្រះរាជអាជ្ញាចង់បានលេខយោងឬក៏យ៉ាងម៉េច?

*(សម្រាករយៈពេលខ្លី)*

[១៤:៣៥:១៨]

បាទគឺជាឯកសារ 19.177, ERN ជាភាសាបារាំងគឺ 00679722, ជាភាសាខ្មែរគឺ 00055252 ខ្ញុំនិយាយអំមិញនិយាយបារាំង តាមពិតមិនមែនបារាំងទេ គឺជាភាសាអង់គ្លេសទេ ព្រោះថាអត់មានសំណៅជាភាសាបារាំងទេ។ គឺទំព័រ៣៨/៤៨ ទំព័រ ជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែរបៀបរបៀបចំឯកសារនេះ រៀងពិបាកយល់ដែរ។ បាទ នៅកន្លែងផ្នែកហ្នឹងទំព័រហ្នឹង លោកនិយាយថា “មានតែ ខៀវ សំផន ទេ ដែលនៅក្នុងប្រទេស”។ ហើយលោកក៏បានបន្ថែមទៀតផងដែរ “ខៀវ សំផន បានចាកចេញក្រោយពេលដែលវៀតណាមចូលមកដល់ហើយទេ”។ តើលោកចាំថាលោកបាននិយាយយ៉ាងដូច្នេះដែរទេ ហើយបើសិនជាលោកនៅចាំនោះលោកអាចធ្វើការកត់សម្គាល់អីបន្តិចបានទេ?

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ ត្រង់ចំណុចនេះយើងខ្ញុំដូចជាមិនបានចាំពិតទេបាទ តែគ្រាន់តែពេលដែលប្រជុំនោះសុំតែគាត់ -- មិនច្បាស់ត្រង់ណេះ -- សមតែគាត់បានលើកថា “គេចេញអស់ហើយនៅតែគាត់ម្នាក់ទេ”។

**ស៖** ហើយពួកគាត់បានសុំឲ្យពួកលោកទាំងអស់គ្នាហ្នឹងដឹកលេណដ្ឋានដើម្បីការពារខ្លួន អ៊ីចឹងមែនទេ?

**ឆ៖** បាទ នោះមែនបាទ។

[១៤:៣៧:៤១]

**ស៖** បាទ ខ្ញុំមានប្រធានបទពីរទៀតចង់និយាយជាមួយលោក ហើយដោយខ្លីទេ ប្រធានបទទី១ និយាយអំពីចម្លើយរបស់លោកទាំងពីរដែលលោកបានផ្តល់ជូនទៅអ្នកស៊ើបអង្កេតដែលបានមកសម្ភាសលោកនៅឆ្នាំ២០០៨ ដែលទទួលបញ្ជាពីសហចៅក្រមស៊ើបអង្កេត។ ទាក់ទងនឹងការចាប់ខ្លួន មិត្តថា ខ្ញុំកត់សម្គាល់ចំណុចមួយ ខ្ញុំចង់ឲ្យលោកធ្វើការកត់សម្គាល់មានប្រតិកម្មនូវឯកសារ E3/472 ចុះថ្ងៃទី៣ មីនា ឆ្នាំ២០០៨ -- ថ្ងៃទី០៥ មីនា ឆ្នាំ២០០៨, ទំព័រទី៤ ជាភាសាបារាំង។ បាទ លោកនិយាយអំពីការចាប់ខ្លួននេះ លោកនិយាយដូចទៅនេះ៖ "អ្នកដែលទទួលបន្ទុកក្នុងការចាប់ខ្លួននោះ ឈ្មោះ មានមនុស្សបួននាក់ហើយមកជិះឡានដែលមានស្លាកក្រហម ផ្លាកលេខនេះតូចពេកពិបាកមើល"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំសូមអានឲ្យអានសម្រង់នេះជាភាសាខ្មែរផងដែរ អ៊ីចឹងលោកអានមើល តើវាដូចនឹងសំណៅជាភាសាបារាំងទេ?

[១៤:៣៩:២៤]

បន្ទាប់មកទៀតលោកបានផ្តល់ព័ត៌មាន ដែលទាក់ទងនឹងស្លាកលេខនេះដែរ នៅក្នុងចម្លើយទី២របស់លោកនោះ ហើយនៅទីនេះក៏លោកបានឆ្លើយដែរម្សិលមិញនេះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកពន្យល់ពីភាពខុសគ្នាដោយច្បាស់លាស់ ដែលថាទី១ នៅក្នុងចម្លើយទី១របស់លោក លោកនិយាយថាស្លាកលេខនេះវាតូចពេកពិបាកមើល ហើយក្រោយមកលោកនិយាយថា ច្បាស់មើលឃើញ។ ហើយឥឡូវអ៊ីចឹងលោកអាចពន្យល់បន្តិចបានទេ ពីភាពផ្ទុយគ្នានេះ ម្តងលោកថាមើលមិនសូវឃើញច្បាស់ ក្រោយមកដឹងថាស្លាកលេខហ្នឹង ស្លាកលេខហ្នឹងលេខប៉ុន្មាន?

**ឆ៖** បាទ សូមអរគុណ។ ម្សិលមិញខ្ញុំបានបញ្ជាក់ហើយមិនមែន ៨៧០ទេ គ្រាន់តែបានឃើញក្រហម ហើយដាក់ថា ម-៧០ អ៊ីចឹង មានពិតមែន។

**ស៖** បាទ សូមអរគុណ។ បាទ សំណួរចុងក្រោយទាក់ទងទៅនឹងព័ត៌មានដែលលោកបានផ្តល់ជូននៅក្នុងប្រវត្តិរូបបដិវត្តន៍របស់លោកដែលមានលេខកូដ 19.177។ បាទ ខ្ញុំចង់និយាយពីទំព័រចុងក្រោយនៃប្រវត្តិរូបរបស់លោកនេះ គឺលេខ ERN ជាភាសាបារាំងគឺ 00813951, ជាភាសាខ្មែរគឺ 00053664។ បាទ ពុំមានសំណៅជាភាសាអង់គ្លេសទេ។ បាទ កន្លែងនេះលោកនិយាយថា "បងប្រុសទី៥របស់ខ្ញុំបានចូលក្នុងកងទ័ពវៀតណាមនៅក្នុងឆ្នាំ១៩៧០ ក៏ប៉ុន្តែឆ្នាំ៧១ គាត់បានចាកចេញពីកងទ័ពវៀតណាមនេះ ហើយត្រឡប់មកផ្ទះវិញ។ ថ្ងៃទី០១ - ៧៤ គាត់ចូលបដិវត្តន៍នៅក្នុងនៅក្នុងយោធា"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើហេតុអ្វីជាបងប្រុសរបស់លោកបានចាកចេញពីកងទ័ព

វៀតណាម?

[១៤:៤២:១៣]

**ឆ៖** បាទ សូមអរគុណ សូមបញ្ជាក់បន្ថែម។ រឿងចំពោះបងប្រុសខ្ញុំ គឺថាអានេះយើងនិយាយទៅតាមប្រពៃណីរបស់ខ្មែរ កាលណោះគាត់បានឆោតល្ងង់ដែរ គឺចូលជាមួយនឹងគេហៅថាវៀតណាមខាងជើង គេហៅថាភាគខាងជើងៗ មកចូលស៊ប់ទៅ ទៅដល់សៀមរាប ដល់ឆ្នាំ៧០ហ្នឹងឯង រហូតដល់ឆ្នាំ៧១ ឪពុកខ្ញុំគាត់ត្រូវឈឺធ្ងន់។ អ៊ីចេះបាត់តែគាត់មួយទេកូនទាំងអស់។ ដូចជាហៅថា ដូចថាអ៊ីចឹងដល់បងខ្ញុំត្រូវមកដល់ពេលថ្ងៃត្រង់ឪពុកខ្ញុំត្រូវដាច់ខ្យល់ស្លាប់ក្នុងថ្ងៃនោះតែម្តង។ នេះក៏គាត់អត់មានធ្វើអីតទៅទៀតទេ ចប់ត្រឹមហ្នឹង។ នេះនិយាយពីហេតុផល។

**ស៖** បាទ ខ្ញុំយល់ -- បើខ្ញុំយល់មិនខុសទេ គឺថាបងប្រុសរបស់លោកត្រឡប់ចូលប្រទេសកម្ពុជាវិញ ត្រឡប់មកស្រុកកំណើតក្រោយពេលដែលឪពុករបស់លោកស្លាប់ ថាមកមិនទាន់ដង្ហើម -- លោកចង់និយាយថា ម៉េចខ្ញុំយល់មិនច្បាស់? ចង់និយាយថា គាត់មកអត់ទាន់ដង្ហើម ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សូមស្តាប់ឲ្យច្បាស់ គឺថាពេលគាត់ទៅ អស់រយៈពេលយូរហើយបាទ។ តែកាលនោះឪពុកខ្ញុំឈឺធ្ងន់រយៈពេល៧ថ្ងៃទេ គាត់មិនអ្នកឈឺរ៉ាំរ៉ៃទេ ឪពុកខ្ញុំ។ អ៊ីចឹងវាដូចចៃដន្យដែរ ថ្ងៃដែលគាត់ត្រូវត្រឡប់មក -- ត្រឡប់ចាកចេញពីទ័ពមកវិញ រត់មកដល់ផ្ទះ គឺថាវេលាថ្ងៃត្រង់នេះឯងបានមកដល់ជួបជុំគ្នា ឪពុកខ្ញុំត្រូវស្លាប់អ៊ីចឹងតែម្តង។ បាទ នេះស្តាប់ឲ្យបានអ៊ីចឹង។ នេះឯង អត់មានទេ ហើយក៏គាត់ឈប់ធ្វើទ័ពត្រឹមណោះ។

[១៤:៤៤:៥០]

**លោក អាកឡូវ វែកគែន៖**

បាទ លោកសាក្សី ខ្ញុំយល់ហើយ។ អ៊ីចឹងខ្ញុំសួរចប់ហើយលោកសាក្សី។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្តីលោក នួន ជា តើមានសំណួរដែលត្រូវសួរសាក្សីរូបនេះទេ? ហើយបើត្រូវសួរតើចំណាយពេលវេលាប្រហែលប៉ុន្មានដែរក្នុងការសួរ?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងនៅពេលតែ៥នាទីទេ។ ប្រហែលជាខ្ញុំសួរ ហើយអាចនឹងសួរឥឡូវ អាចនឹងក្រោយមកគឺ

តទៅ ធី.អឹម.អឹម បាទ។ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណ។ ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទេ។ ម្សិលមិញនេះ គេសួរលោកអំពីហេតុការណ៍មួយចំនួននៅខែមេសា ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ លោកចាំទេដែលថា លោកឈរនៅផ្លូវលេខ៦ គេសួរលោកថាតើកងទ័ពខាងខ្មែរក្រហមនោះបានជ្រើសរើសអតីតទាហាន ឬក៏មន្ត្រី លន់ នល់ ចេញពីក្រុមមនុស្សដែលត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ? លោកបានឆ្លើយថា លោកមិនដែលឮរឿង លោកមិនដែលបានឃើញរឿងហ្នឹងទេ។ ខ្ញុំសួរលោកថា តើពេលក្រោយមក តើលោកបានឮថាមន្ត្រី ឬក៏យោធា លន់ នល់ ត្រូវបានគេស្រង់ចេញ ឬក៏ដកយកចេញពីក្រុមមនុស្សដែលចេញពីភ្នំពេញដែរឬទេ?

[១៤:៤៦:៣៤]

**លោក ស៊ឹម ហោ៖**

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបានជម្រាបប្រាប់អង្គជំនុំជម្រះហើយថា ការដកចេញដោយឡែកៗ ថាប្រជាពលរដ្ឋផ្សេង ឯទាហានស៊ីវិលអីនោះផ្សេង។ អានោះគឺខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថាគេបានជម្លៀសប្រជាជនចេញពីទីក្រុង គឺឃើញជាបន្តបន្ទាប់ពិតមែន ក្រោយថ្ងៃរំដោះ។

**ស៖** ឥឡូវយើងត្រឡប់ទៅក្រោយវិញ តាមពេលវេលា។ ម្សិលមិញលោកបាននិយាយថា លោកបានចូលរួមក្នុងសមរភូមិជាមួយកងទ័ព លន់ នល់ ចាប់ពីឆ្នាំ១៩៧០, ៧១, ៧២ ដល់ ៧៣, ៧៤។ តើអង្គភាពរបស់លោកបានវាយប្រហារនៅក្នុង -- ដែលវាយប្រហារធ្លាប់បានចាប់ខ្លួន ឬក៏ចាប់ទាហានចាប់កងទ័ពពួក លន់ នល់ បានដែរឬទេ?

**ឆ៖** ពេលដែលខ្ញុំរស់នៅជាមួយនឹងកងវរៈកន្លងទៅក្នុងការតបតគ្នានោះ គឺថាក្នុងកងវរៈរបស់យើងខ្ញុំគឺមានការចាប់ខ្លួនបានមួយពីរដែរនៅឯខេត្តកំពង់ធំនោះ អានោះនៅលើកងវរៈទេ។ តែចំណែកខ្ញុំគឺអត់ទេ មិនបានចាប់ទេ គ្រាន់តែបានឃើញ។ ចាប់ប្រគល់ឲ្យប្រធានវរសេនាតូច។

**ស៖** ថាតើលោកនៅចាំទេ តើគេយកទាហាន លន់ នល់ ដែលគេចាប់ខ្លួនបានហ្នឹង ទៅយកទៅធ្វើអ្វី ឬក៏គេដោះស្រាយម៉េច?

[១៤:៤៨:៤០]

**ឆ៖** ត្រង់នោះ ដែលថាចំពោះបញ្ហាទ័ពប្រគល់ឲ្យមេរួចហើយ មិនដឹងគេបញ្ជូនទៅខាងណា

យើងខ្ញុំមិនបានឃើញ និងមិនបានដឹង។

**ស៖** នៅពេលដែលលោកជាយោធារបស់បដិវត្តន៍នោះ តើលោកធ្លាប់បានឃើញគេសម្លាប់ពួកមន្ត្រី ឬក៏ទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានឃើញទេត្រង់អង្គាល់ដូចថា សម្លាប់ដូចចាប់បានមកផ្ទាល់ដៃ តែគ្រាន់ក្នុងការច្បាំងបាញ់ទៅវិញទៅមកនោះ វាឃើញៗស្លាប់។ ក្រោយមកដែរថាយើងទៅយកសាកសពអីចេះគឺមានស្លាប់។ មិនថាខាងណោះ ខាងណេះទេ។ ប៉ុន្តែគ្រាន់តែថាច្រើន និងតិច។

**ស៖** តើជាចម្លើយរបស់លោកទេ គឺថាទាហាន លន់ នល់ ដែលលោកបានឃើញនោះ គឺអ្នកដែលស្លាប់ក្នុងការប្រយុទ្ធទេ?

[១៤:៥០:០៩]

**ឆ៖** បាទ ឃើញក្នុងការប្រយុទ្ធគ្នាទៅវិញទៅមកទេ ដែលស្លាប់។ មិនបានឃើញផ្ទាល់ដែលគេចាប់ចងយកទៅវៃនោះ អត់បានឃើញផ្ទាល់ទេ អារឿងអីចុះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់ការសួរសំណួររបស់ខ្ញុំហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា កិច្ចពិភាក្សាដេញដោលលើភស្តុតាងស្តាប់សក្ខីកម្មសាក្សីរូបនេះ គឺដល់ពេលសម្រាកហើយ។ ដោយឡែកក្រោយពេលសម្រាកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើកិច្ចប្រជុំរៀបចំសវនាការដែលព្រឹកមិញធ្វើមិនទាន់ចប់។ អ៊ីចឹងនៅចុងម៉ោងថ្ងៃនេះ គឺអង្គជំនុំជម្រះនឹងបន្តធ្វើកិច្ចប្រជុំរៀបចំសវនាការបញ្ចប់ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនកាលពីព្រឹកមិញ។

[១៤:៥១:០៨]

លោក ស៊ឹម ហោ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះ បានចប់ហើយ។ ហើយវត្តមានរបស់លោកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លែងមានភាពចាំបាច់ទៀតហើយដូច្នេះ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដែលមានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះរយៈពេល២ថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ ខិតខំប្រឹងប្រែងអស់ពី

លទ្ធភាព និងសមត្ថភាពរបស់ខ្លួន។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្ដីនេះ។ ហើយលោក ស៊ឹម ហោ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ ហើយទទួលបាននូវសេចក្ដីសុខ សេចក្ដីចម្រើននៅក្នុងឆាកជីវិតរបស់លោក ហើយលោកវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

បាទ ហើយសវនាការនេះ ដល់ពេលសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកលើការសវនាការលើភស្តុតាងសម្រាកពេលនេះ ហើយត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៧ ខែមិថុនា ឆ្នាំ២០១៣ ទៀត ចាប់ពីម៉ោងប្រាំបួនព្រឹក។ ហើយថ្ងៃសវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-384 សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

សូមអញ្ជើញបាទ!

[១៤:៥២:៣៥]

**លោក អាកទូរ វ៉ែកកែន៖**

បាទ លោកប្រធាន សូមអរគុណ។

ខ្ញុំសូមបញ្ជាក់ថា លោក ខៀវ សំផន គាត់សូមអនុញ្ញាតទៅមន្ទីរឃុំឃាំងវិញ ពីព្រោះថានៅពេលក្រោយនោះ គឺថាជាសវនាការពាក់ព័ន្ធនឹងកិច្ចប្រជុំទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះរៀបចំរួចហើយ គ្រាន់តែនិតីវិធីប្រព្រឹត្តទៅវាមិនដល់តែប៉ុណ្ណឹងទេ។

មន្ត្រីរដ្ឋតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស៊ឹម ហោ វិលត្រឡប់ទៅកាន់គោលដៅដែលគាត់មានបំណងចង់ ឬក៏លំនៅដ្ឋានរបស់គាត់វិញបានហើយ ហើយលោក ម៉ម រិទ្ធា ដែលជាមេធាវីប្រឹក្សាសាក្សី ក៏អាចចាកចេញ និងវិលត្រឡប់ទៅវិញបានដែរ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ នៅថ្ងៃចន្ទ ទី១៧ ខែមិថុនា ឆ្នាំ២០១៣ ឲ្យមុនម៉ោងប្រាំបួនព្រឹក។

[១៤:៥៣:៣៩]

ហើយដោយឡែក លោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី រហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចប្រជុំរៀបចំសវនាការ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៤ នាទី)*